ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ និងយុទ្ធសាស្ត្រ ស្ដីពី បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ



ខែឧសភា ឆ្នាំ២០១៨

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ថាសមត្ថភាពធនធានមនុស្សខាងផ្នែកបំណិនសតវត្សរ៍ទី២១ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (បពស) គឺជាកត្តាជំរុញឧត្តមភាពប្រកួតប្រជែងរបស់ប្រទេស។ សមត្ថភាពទាំងនេះជួយឱ្យប្រជាជនបង្កើតចំណេះដឹងថ្មីៗ និងប្រែក្លាយចំណេះដឹងទាំងនេះទៅជាការអនុវត្តថ្មីៗ ដើម្បីគាំទ្រដល់ការធ្វើអន្តរកម្មសេដ្ឋកិច្ចរបស់ប្រទេស ពីការធ្វើពាណិជ្ជកម្មជាលក្ខណៈដោះដូរទំនិញ ទៅជាការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្ម ដែលប្រើប្រាស់ចំណេះដឹងកម្រិតខ្ពស់។

ដើម្បីពន្លឿនការធ្វើអន្តរកម្មទៅរកសេដ្ឋកិច្ចផ្អែកលើចំណេះដឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវគោលនយោបាយជាច្រើន ដើម្បីបង្កើតនូវបរិយាកាសអំណោយផលតាមរយៈការប្រើប្រាស់ បពស។ ស្របពេលជាមួយគ្នានេះ វិស័យ បពស នៅកម្ពុជាបានសម្រេចវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រីកសេវាកម្មនៅទូទាំងប្រទេស។ ការអភិវឌ្ឍទាំងនេះផ្តល់នូវកាលានុវត្តភាពសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើកំណែទម្រង់ និងទំនើបកម្មវិស័យអប់រំ ដោយរាប់បញ្ចូលទាំងសមត្ថភាពផ្នែក បពស ដល់ប្រជាជនកម្ពុជាគ្រប់រូប។

ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ថា បពស គឺជាកាតាលីករចម្បងមួយក្នុងការលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សសម្រាប់សេដ្ឋកិច្ចសតវត្សរ៍ទី២១ ដែលតម្រូវឱ្យវិស័យអប់រំចាំបាច់ត្រូវរៀបចំផែនការ បពស ដែលមានលក្ខណៈជាប្រព័ន្ធ ពោលគឺការកសាងហេដ្ឋារចនាសម្ព័ន្ធ និងអនុវត្តកម្មវិធីផ្នែក បពស ដើម្បីធានានូវប្រសិទ្ធភាព និងនិរន្តរភាព ងាកចេញពីការអនុវត្តក្នុងស្ថានភាពបច្ចុប្បន្នដែលជារឿយៗកម្មវិធី បពស ត្រូវបានអនុវត្តដោយពុំមានការសម្របសម្រួលច្បាស់លាស់។

គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពី បពស ក្នុងវិស័យអប់រំនេះត្រូវបានរៀបចំឡើងដោយឆ្លងកាត់ការពិគ្រោះយោបល់ជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធវិស័យអប់រំ។ ឯកសារនេះត្រូវបានតាក់តែងឡើងដើម្បីជួយដល់ការគ្រប់គ្រងវិស័យ បពស ក្នុងការធ្វើទំនើបកម្មការងារអភិបាលកិច្ច និងការងារគ្រប់គ្រង ព្រមទាំងបង្កើនតម្លាភាព និងគណនេយ្យភាព។ គោលនយោបាយ និងយុទ្ធសាស្ត្រនេះគាំទ្រដល់ការកៀរគរធនធាន និងរៀបចំផែនការផ្អែកលើភស្តុតាងជាមូលដ្ឋាន ក៏ដូចជាបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងរដ្ឋបាលវិស័យអប់រំ។ លើសពីនេះ គោលនយោបាយ និងយុទ្ធសាស្ត្រនេះក៏ផ្តល់ការគាំទ្រដល់ការប្រើប្រាស់វិធីសាស្ត្រគរុកោសល្យបែបថ្មីដោយប្រើប្រាស់ បពស។

ជាមួយនឹងការទទួលខុសត្រូវក្នុងការលើកកម្ពស់វិស័យអប់រំ យើងទាំងអស់គ្នាចាំបាច់ត្រូវអនុវត្តដោយការសម្របសម្រួលគាំទ្រគ្នាល្អពីគ្រប់អ្នកពាក់ព័ន្ធ ក្រសួងសង្ឃឹមថានឹងអាចទាញប្រយោជន៍ពី បពស ដើម្បីរួមចំណែកកសាងប្រព័ន្ធអប់រំឱ្យកាន់តែល្អប្រសើរ ក្នុងគោលដៅរៀបចំសិស្សនិស្សិតឱ្យក្លាយជាអ្នកជំនាញ ដែលប្រទេសជាតិកំពុងត្រូវការ។

ថ្ងៃចន្ទ ៨ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

## អក្សរកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBR&D | Capacity Building, Research and Development Fund | មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (មូលនិធិ ស.អ.) |
| DIT | Department of Information Technology | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន (នា.បវព) |
| DoE | District Office of Education, Youth and Sport | ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ខណ្ឌ ស្រុក |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| HEI | Higher Education Institution | គ្រឹះស្ថានឧត្តមសិក្សា |
| HRMIS | Human Resource Management Information System | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស |
| ICT | Information and Communication Technology | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (បពស) |
| IT | Information Technology | បច្ចេកវិទ្យាព័ត៌មាន |
| LMS | Learning Management System | ប្រព័ន្ធគ្រប់គ្រងការសិក្សា |
| LSS | Lower Secondary School | សាលាមធ្យមសិក្សាបឋមភូមិ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ) |
| MoEYS | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក) |
| MPTC | Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ.) |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ (វជអ) |
| OER | Open Educational Resources | ធនធានអប់រំបើកទូលាយ |
| PPP | Public Private Partnership | ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន |
| PoE | Provincial Department of Education, Youth and Sport | មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| STEM | Science, Technology, Engineering and Mathematics | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| TTC | Teacher Training Center | សាលាគរុកោសល្យ និងវិក្រឹតការ |
| TVET | Technical and Vocational Education and Training | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| USO | Universal Service Obligation | កាតព្វកិច្ចសេវាសកល |
| USS | Upper Secondary School | សាលាមធ្យមសិក្សាទុតិយភូមិ |

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (បពស) នឹងក្លាយជាឧបករណ៍ដ៏សំខាន់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មរបស់ប្រទេស និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រឹងបរិយាកាសអំណោយផល បង្កភាពងាយស្រួលដល់ការយក បពស មកប្រើប្រាស់នៅគ្រប់សកម្មភាពទាំងអស់នៃការរស់នៅរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យអភិវឌ្ឍ និងធ្វើទំនើបកម្មឧស្សាហកម្មរបស់ប្រទេស ពីឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មទៅជាឧស្សាហកម្មផ្អែកលើពុទ្ធិ និងបំណិនត្រឹមឆ្នាំ២០២៥ តាមរយៈការបង្កើតនូវសេដ្ឋកិច្ចឧស្សាហកម្មទំនើបដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា និងពុទ្ធិជាមូលដ្ឋាន។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្ពុជាត្រូវពឹងអាស្រ័យលើការផ្គត់ផ្គង់ធនធានមនុស្សដែលមានលក្ខណៈសម្បត្តិសមស្រប និងសមត្ថភាពកម្រិតខ្ពស់ជាមួយនឹងចំណេះដឹងទូលំទូលាយផ្នែក បពស ចាប់ពីការប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃរហូតដល់ការបង្កើតចំណេះដឹង និងប្រព័ន្ធច្នៃប្រឌិតថ្មីៗជាដើម។ ស្របតាមរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព យើងចាំបាច់ត្រូវទាញប្រយោជន៍ពី បពស ដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំដោយជួយគាំទ្រលើការស្រាវជ្រាវ និងការបង្កើតចំណេះដឹងក៏ដូចជាបង្កភាពងាយស្រួលដល់ការទទួល និងផ្សព្វផ្សាយព័ត៌មាន។ បច្ចេកវិទ្យានេះនឹងបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន ក៏ដូចជាបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំតាមរយៈការបង្កើតប្រព័ន្ធពិនិត្យតាមដាន និងអភិបាលកិច្ចដែលមានលក្ខណៈច្បាស់លាស់ជាងមុន។

ភាពចាំបាច់ក្នុងការបង្កើនការប្រើប្រាស់ បពស ក្នុងការងារគ្រប់គ្រង និងអភិបាលកិច្ចជាប្រចាំរបស់ក្រសួងក្នុងការបង្រៀន និងរៀន តម្រូវឲ្យមានការពង្រឹងសមត្ថភាពគាំទ្រផ្នែក បពស ក្នុងក្រសួងអប់រំ យុវជន និងកីឡាទាំងមូល។ ការគាំទ្រនេះគឺចាំបាច់ណាស់សម្រាប់គ្រប់គ្រងស្ថានការណ៍វិវឌ្ឍន៍ផ្នែក បពស ដែលមានការប្រែប្រួលគួរឱ្យកត់សម្គាល់នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងដើម្បីពង្រីកការប្រើប្រាស់ បពស ក្នុងក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡា។ ភស្តុតាងបង្ហាញកាន់តែច្បាស់ថាគេមិនអាចគ្រប់គ្រង និងគាំទ្រដល់អន្តរាគមន៍ បពស ដែលប្រើប្រាស់ដាច់ដោយឡែកតាមគម្រោងនីមួយៗទៀតទេ។ ដូច្នេះគោលនយោបាយ និងយុទ្ធសាស្ត្រនេះមានគោលបំណងប្រើប្រាស់អភិក្រមដែលមានលក្ខណៈជាប្រព័ន្ធ ដោយដាក់ចេញនូវដំណើរការប្រព័ន្ធការងារដែលមានលក្ខណៈស្តង់ដា និងកែលម្អការសម្របសម្រួលជាអាទិភាព និងការវិនិយោគនានា ក្នុងគោលបំណងបង្កើនអត្ថប្រយោជន៍ដែលទទួលបានពីការវិនិយោគឱ្យដល់កម្រិតអតិបរមាសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា និងដើម្បីឆ្លើយតបចំពោះតម្រូវការ បពស ថ្មីៗនៅក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការវិភាគស៊ីជម្រៅលើឯកសារពាក់ព័ន្ធ ការចុះស្រាវជ្រាវដល់មូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានា ដើម្បីប្រមូលព័ត៌មានសម្រាប់រៀបចំ "អភិក្រមជាប្រព័ន្ធ" អភិវឌ្ឍចេញជាគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នេះឡើង។ ខណៈពេលដែលគោលនយោបាយដែលដាក់ចេញក្នុងឯកសារនេះ ផ្តោតការយកចិត្តទុកដាក់លើសមិទ្ធផលអប់រំសំខាន់ៗដែលអាចសម្រេចបាន យុទ្ធសាស្ត្រចម្បងចំនួនប្រាំត្រូវបានរៀបចំឡើង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តអភិក្រមជាប្រព័ន្ធ រួមមាន៖ ១. ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់បណ្តាញ និងសម្ភារៈបច្ចេកទេស ២. អភិបាលកិច្ច និងការគ្រប់គ្រង ៣. ការផ្តល់មូលនិធិសម្រាប់ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ ៤. ធនធាន បពស សម្រាប់ការបង្រៀន និងរៀន ៥. ការអភិវឌ្ឍធនធានមនុស្ស ដែលផ្នែកទាំងនេះពាក់ព័ន្ធគ្រប់អនុវិស័យទាំងអស់ក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា យល់ពីកម្រិតនៃធនធានដែលត្រូវការជាចាំបាច់សម្រាប់ពន្លឿនការប្រើប្រាស់ បពស ក្នុងវិស័យអប់រំ និងយល់ពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ការគាំទ្រ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការយន្តការច្បាស់លាស់ ដើម្បីពង្រឹងការគ្រប់គ្រងភាពជាដៃគូទាំងនេះឱ្យកាន់តែមានភាពល្អប្រសើរ សម្រេចឱ្យបានលទ្ធផលជាវិជ្ជមានបន្ថែមទៀត។ គោលនយោបាយ និងយុទ្ធសាស្ត្រនេះប្រើប្រាស់មេរៀនដែលទទួលបានពីគម្រោងអភិវឌ្ឍន៍កន្លងមកនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាពីបណ្តាប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ ក្រសួងអប់រំ យុវជន និងកីឡា មានការប្រុងប្រយ័ត្នក្នុងការបញ្ចៀសការធ្វើការងារត្រួតគ្នា ដូចជាការបង្កើតគំរូផ្សេងៗគ្នាសម្រាប់គោលបំណងតែមួយ ឬការសាកល្បងដែលមិនមាននិរន្តរភាពក្រោយគម្រោងត្រូវបានបញ្ចប់ជាដើម។ ដៃគូពាក់ព័ន្ធត្រូវបានលើកទឹកចិត្តក្នុងការអនុវត្តគម្រោងនានា ដោយបន្សុីឱ្យស្របនឹងយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងក្នុងការបំពាក់ សម្ភារៈបច្ចេកទេសផ្នែករឹង (Hardware) និងកម្មវិធីផ្នែកទន់ (Software) ដើម្បីឱ្យការវិនិយោគទាំងនេះអាចបញ្ចូលទៅក្នុងប្រព័ន្ធអប់រំនៅពេលចប់អន្តរាគមន៍របស់ដៃគូ។

លើសពីនេះក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងអភិវឌ្ឍសមត្ថភាពដឹកនាំនវានុវត្តន៍ដោយប្រើប្រាស់ បពស សម្រាប់វិស័យអប់រំទាំងមូល។ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងវាយតម្លៃលើគុណតម្លៃនៃបទពិសោធន៍ដែលទទួលបានពីប្រទេសដទៃសម្រាប់អនុវត្តក្នុងបរិបទប្រទេសកម្ពុជា និងផ្តល់ប្រឹក្សាដល់អង្គភាពជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា អំពីជម្រើសដែលអាចមាន ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់អង្គភាពទាំងនោះតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

## ចក្ខុវិស័យ

ផែនការនេះមានចក្ខុវិស័យឱ្យក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់សម្រាប់ថ្នាក់ដឹកនាំ ធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាងជាក់ស្តែង និងលើកកម្ពស់ការបង្រៀននិងរៀន សម្រាប់សិស្សនិស្សិតគ្រប់រូបបញ្ចប់ការសិក្សាឱ្យមានគំនិតនវានុវត្តន៍ច្នៃប្រឌិតប្រកបដោយក្រមសីលធម៌ អាចប្រកួតប្រជែងបានក្នុងសង្គមព័ត៌មាន និងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ។

## គោលដៅ

គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំមានគោលដៅចំនួនពីរ៖

១-ក្រសួងអប់រំ យុវជន និងកីឡា នឹងប្រើប្រាស់ដំណើរការគ្រប់គ្រង និងបែបបទការងារថ្មី ដើម្បីធ្វើទំនើបកម្មការអនុវត្តការងារ និងបង្កើនប្រសិទ្ធភាព តម្លាភាព ភាពស័ក្តិសិទ្ធិនៃអភិបាលកិច្ច និងការពិនិត្យតាមដានលទ្ធផលការងារក្នុងវិស័យអប់រំ។

២-ក្រសួងអប់រំ យុវជន និងកីឡា នឹងបញ្ជ្រាបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ឱ្យក្លាយជាឧបករណ៍សម្រាប់បង្រៀននិងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំទាំងមូលសំដៅបំប៉នសិស្ស និស្សិតនូវចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សរ៍ទី២១។

# គោលការណ៍គោលនយោបាយ

១ ក្រសួងអប់រំ យុវជន និងកីឡា នឹងជានាឱ្យសិស្សនិស្សិតកម្ពុជាគ្រប់រូបដែលបញ្ចប់ការអប់រំក្នុងប្រព័ន្ធអាចប្រើប្រាស់ចំណេះដឹង និងបំណិន បពស ដើម្បីមានលទ្ធភាពអាចបន្តការសិក្សា និងការបំពេញការងារវិជ្ជាជីវៈ។

២ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀន និងរៀននៅតាមមជ្ឈមណ្ឌលគរុកោសល្យ សាលារៀន និងគ្រឹះស្ថានអប់រំដទៃទៀតតាមរយៈការប្រើប្រាស់ឧបករណ៍ បពស និងធនធានអប់រំអេឡិចត្រូនិក។

៣ ក្រសួងអប់រំ យុវជន និងកីឡា នឹងប្រើប្រាស់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (E-Learning) ដើម្បីគាំទ្រឱ្យមានការផ្តល់សេវាអប់រំដល់គ្រប់អនុវិស័យអប់រំសម្រាប់សិស្សនិស្សិត និងការអភិវឌ្ឍសមត្ថភាពស្ថាប័នក៏ដូចជាការរៀនពេញមួយជីវិត។

៤ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើនប្រសិទ្ធភាពក៏ដូចជាសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងការចែករំលែកចំណេះដឹងតាមរយៈការប្រើប្រាស់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធ រួមទាំងបង្កើនសមត្ថភាពក្នុងការងាររដ្ឋបាលអប់រំ ប្រតិបត្តិការ និងការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល។

៥ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើតនូវបទដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំ និងតភ្ជាប់បណ្តាញហើយនឹងបញ្ជ្រាបទៅគ្រប់អង្គភាព ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធតភ្ជាប់ផ្ទៃក្នុងតែមួយដែលអាចទំនាក់ទំនងគ្នាបាន។ ប្រព័ន្ធនេះនឹងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់បណ្តាញផ្ទៃក្នុង និងសុវត្ថិភាពផ្នែកព័ត៌មានវិទ្យាគ្រប់គ្រាន់ ព្រមទាំងអាចប្រើប្រាស់ក្នុងទម្រង់ក្រៅបណ្តាញ (Offline) ដើម្បីធានាបាននូវភាពធន់របស់ប្រព័ន្ធ។

៦ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់អាទិភាពដល់ការប្រើប្រាស់កម្មវិធីផ្អែកទន់លើប្រព័ន្ធកូដចំហ (Open Source Software) និងកម្មវិធីជាភាសាខ្មែរសម្រាប់ការបង្រៀន និងរៀន ហើយក្នុងពេលជាមួយគ្នាក្រសួងខិតខំធានាឱ្យមានការគោរពទៅតាមច្បាប់ស្តីពីសិទ្ធិថតចម្លងរបស់កម្ពុជា។ រាល់សំណើអន្តរាគមន៍ដែលពាក់ព័ន្ធនឹង បពស ទាំងអស់ត្រូវបញ្ចូលការវិភាគលើចំណាយសរុបរួមរបស់គម្រោង ឬកម្មវិធី ដើម្បីផ្តល់ព័ត៌មានដល់ក្រសួងអប់រំ យុវជន និងកីឡា អំពីជម្រើសនានា មុនចាប់ផ្តើមអនុវត្តគម្រោង ឬកម្មវិធីទាំងនោះជាផ្លូវការ ក្នុងគោលបំណងធានាឱ្យបានភាពជាម្ចាស់សម្រាប់ថវិកាប្រតិបត្តិការ។

៧ ក្រសួងអប់រំ យុវជន និងកីឡា នឹងលើកកម្ពស់ការយល់ដឹងអំពីអក្ខរកម្មមេឌៀ ឯកជនភាពរបស់អ្នកប្រើប្រាស់ និងការប្រើប្រាស់ បពស ប្រកបដោយក្រមសីលធម៌តាមរយៈការទប់ស្កាត់រាល់ទម្រង់ទាំងអស់នៃការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិត និងការប្រើប្រាស់បច្ចេកវិទ្យាដែលពុំមានសុវត្ថិភាព។

៨ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់ធនធានហិរញ្ញវត្ថុចាំបាច់ដើម្បីគាំទ្រដល់ការប្រើប្រាស់ បពស ក្នុងវិស័យអប់រំ ដោយប្រើប្រាស់ថវិការដ្ឋ និងធ្វើការសម្របសម្រួលភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងការគាំទ្ររបស់ដៃគូអភិវឌ្ឍនានាសម្រាប់រ៉ាប់រងចំណាយមូលធននិងចំណាយចរន្ត។

# យុទ្ធសាស្ត្រ

ការវិភាគបឋមលើគោលនយោបាយ និងយុទ្ធសាស្ត្រនេះផ្តោតលើអន្តរាគមន៍ជាយុទ្ធសាស្ត្រចំនួនប្រាំ ដូចបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖




គោលនយោបាយនេះដាក់ចេញនូវទិសដៅរួម ដោយគោលនយោបាយនីមួយៗមានអន្តរាគមន៍ជាយុទ្ធសាស្ត្រមួយឬច្រើន។ អភិក្រមដែលភ្ជាប់ទំនាក់ទំនងអន្តរាគមន៍មានលក្ខណៈស្រដៀងគ្នាជាប្រព័ន្ធបែបនេះ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ដើម្បីសម្រេចលទ្ធផលដែលចង់បានប្រកបដោយប្រសិទ្ធភាព។

អន្តរាគមន៍នីមួយៗមានយុទ្ធសាស្ត្រជាច្រើនដែលត្រូវបានរៀបចំលម្អិត ចេញជាយុទ្ធសាស្ត្ររយៈពេលខ្លីនិងរយៈពេលមធ្យម។ យុទ្ធសាស្ត្រទាំងនេះត្រូវបានរៀបចំទៅតាមអន្តរាគមន៍ រួមមាន៖

## អន្តរាគមន៍ជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រសំខាន់ៗ

### ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ទំនាក់ទំនង និងសម្ភារៈបច្ចេកទេស

- ប្រើប្រាស់ប្រព័ន្ធ បពស និងការរៀបចំតបណ្តាញ ដែលមានលក្ខណៈជាប្រព័ន្ធរួមមួយ ដើម្បីបង្កើនផលិតភាព
- បំពាក់សាលាមធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យនូវសម្ភារៈបច្ចេកទេស និងការងាររៀបចំតបណ្តាញតាមស្តង់ដា
- បំពាក់អង្គភាពថ្នាក់ក្រោមជាតិរបស់ក្រសួង អ.យ.ក នូវសម្ភារៈបច្ចេកទេស និងការរៀបចំប្រព័ន្ធតាមស្តង់ដា
- បញ្ចូលកម្រិតនៃការបញ្ជូនទិន្នន័យរបស់បណ្តាញ (Network Bandwidth) រួមគ្នាដើម្បីបង្កើនប្រសិទ្ធភាពការងារ

### អភិបាលកិច្ច និងការគ្រប់គ្រង

- ជំរុញឱ្យមានការប្រើប្រាស់ ការកៀរគរធនធាន និងការរៀបចំផែនការ ផ្អែកតាមភស្តុតាងច្បាស់លាស់តាមរយៈការបង្កភាពងាយស្រួលដល់ការទទួលបានទិន្នន័យ ព័ត៌មាន និងការវិភាគទិន្នន័យ
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងតាមរយៈការប្រើប្រាស់ដំណើរការប្រតិបត្តិការដោយប្រើប្រព័ន្ធ បពស តាមស្ថាប័នឱ្យមានលក្ខណៈស្តង់ដា
- ធ្វើលទ្ធកម្មកម្មវិធីផ្នែកទន់ដែលចាំបាច់ និងដាក់ចេញនីតិវិធីសម្រាប់ដំណើរការប្រព័ន្ធ បពស សំខាន់ៗរបស់ក្រសួង អ.យ.ក
- សម្របសម្រួល និងធ្វើការត្រួតពិនិត្យលើគ្រប់សកម្មភាព បពស ទាំងអស់ដែលកើតមានក្នុងក្របខ័ណ្ឌឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រនេះ
- អភិវឌ្ឍ ឬធ្វើលទ្ធកម្មកម្មវិធីផ្នែកទន់ដែលចាំបាច់សម្រាប់គាំទ្រដល់ការងារគ្រប់គ្រង

### ការផ្តល់មូលនិធិសម្រាប់ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ

- ផ្តល់ធនធានហិរញ្ញវត្ថុរយៈពេលវែងជាប់ជាប្រចាំ ដើម្បីគាំទ្រដល់ដំណើរការ បពស ក្នុងក្របខ័ណ្ឌក្រសួង អ.យ.ក

### ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងរៀន

- ធ្វើទំនើបកម្មកម្មវិធីសិក្សា ដើម្បីបញ្ចូលចំណេះដឹង បពស និងបំណិនសតវត្សរ៍ទី២១
- ធ្វើលទ្ធកម្ម និង/ឬអភិវឌ្ឍធនធានអប់រំអេឡិចត្រូនិក (E-Resources) សម្រាប់ផ្តល់ការគាំទ្រដល់ការបង្រៀន និងរៀន (មាតិកាអប់រំអេឡិចត្រូនិក)
- អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់សៀវភៅមគ្គុទ្ទេសក៍ និងឧបករណ៍នានាសម្រាប់ជំនួយដល់គ្រូលើវិធីសាស្ត្រគរុកោសល្យដោយប្រើប្រាស់ បពស សម្រាប់ការបង្រៀននៅតាមសាលាគរុកោសល្យ និងសាលាមធ្យមសិក្សាទុតិយភូមិ
- លើកទឹកចិត្តឱ្យមានការធ្វើស្វ័យសិក្សាតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS)

### ការអភិវឌ្ឍធនធានមនុស្ស

- បណ្តុះបណ្តាលគ្រូមុខវិជ្ជាឯកទេស បពស សម្រាប់គ្រប់សាលាមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិ
- លើកកម្ពស់លទ្ធភាពទទួលបានការបណ្តុះបណ្តាល និងវិក្រឹតការដោយប្រើប្រាស់ បពស ក្នុងការបង្រៀន និងរៀន នៅតាមសាលាគរុកោសល្យ និងវិធីសាស្ត្រនេះក៏ត្រូវបានប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាលគ្រូ
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ដើម្បីផលិតធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយគុណភាពខ្ពស់ និងឆ្លើយតបតាមតម្រូវការ
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ក្នុងការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគ្រប់គ្រងប្រព័ន្ធ និងសេវាកម្មបច្ចេកវិទ្យានានា
- បង្កើនសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សាដើម្បីផ្តល់ការបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិក

| ១. ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ទំនាក់ទំនង និងសម្ភារៈបច្ចេកទេស | | |
|---|---|---|
| យុទ្ធសាស្ត្រ១.១ ប្រើប្រាស់ប្រព័ន្ធ បពស និងការរៀបចំតបណ្តាញដែលមានលក្ខណៈជាប្រព័ន្ធរួមមួយដើម្បីបង្កើនផលិតភាព | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ១.១.១ | ការវិភាគមុខងារ បពស ក្នុងអង្គភាពជំនាញរបស់ក្រសួង នៅថ្នាក់ជាតិចំនួន៥០%។ | ការវិភាគមុខងារ បពស ត្រូវបានបញ្ចប់គ្រប់អង្គភាពថ្នាក់ជាតិរបស់ក្រសួង អ.យ.ក។ |
| ១.១.២ | ការបង្កើតបណ្តាញផ្ទៃក្នុង និងមជ្ឈមណ្ឌលទិន្នន័យរួមសម្រាប់រក្សាបម្រុងទុកទិន្នន័យដើម្បីទាញយកទៅប្រើប្រាស់ និងកន្លែងរក្សាទុកទិន្នន័យស្របតាមស្តង់ដាឧស្សាហកម្ម (មជ្ឈមណ្ឌលទិន្នន័យ)។ | នាយកដ្ឋានជំនាញរបស់ក្រសួង អ.យ.ក ត្រូវបានតភ្ជាប់បណ្តាញជាមួយគ្នា និងភ្ជាប់ទៅកាន់មជ្ឈមណ្ឌលទិន្នន័យ និងកន្លែងរក្សាទុកទិន្នន័យរួមមួយរបស់ក្រសួង។ |
| យុទ្ធសាស្ត្រ១.២ បំពាក់សាលាមធ្យមសិក្សាទុតិយភូមិ និងសាលាគរុកោសល្យនូវសម្ភារៈបច្ចេកទេស និងការរៀបចំតបណ្តាញទៅតាមស្តង់ដា | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ១.២.១ | រៀបចំស្តង់ដាសម្រាប់សម្ភារៈបច្ចេកទេស និងតភ្ជាប់ទំនាក់ទំនង រវាងគ្រឹះស្ថានអប់រំនានាតាមរយៈបណ្តាញ។ សាលាមធ្យមសិក្សាទុតិយភូមិ៥០% និងសាលាគរុកោសល្យទាំងអស់ទទួលបានការបំពាក់សម្ភារៈបច្ចេកទេសតាមស្តង់ដា។ | សាលាមធ្យមសិក្សាទុតិយភូមិដែលនៅសល់៥០% ទទួលបានសម្ភារៈបច្ចេកទេសស្របតាមស្តង់ដារបស់ក្រសួង អ.យ.ក។ |
| ១.២.២ | អ្នកពាក់ព័ន្ធមកពីវិស័យផ្សេងក្រៅពីវិស័យសាធារណៈ ៨០% ដែលផ្តល់សម្ភារៈបច្ចេកទេស គោរពទៅតាមគោលការណ៍ណែនាំយថាប្រភេទរបស់ក្រសួង អ.យ.ក។ | អ្នកពាក់ព័ន្ធមកពីវិស័យផ្សេងក្រៅពីវិស័យសាធារណៈ ១០០% ដែលផ្តល់សម្ភារៈបច្ចេកទេស គោរពទៅតាមគោលការណ៍ណែនាំយថាប្រភេទរបស់ក្រសួង អ.យ.ក។ |
| យុទ្ធសាស្ត្រ ១.៣ បំពាក់អង្គភាពថ្នាក់ក្រោមជាតិរបស់ក្រសួង អ.យ.ក នូវសម្ភារៈបច្ចេកទេស និងការរៀបចំប្រព័ន្ធទៅតាមស្តង់ដា | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ១.៣.១ | គ្រប់អង្គភាពថ្នាក់ក្រោមជាតិត្រូវបានបំពាក់សម្ភារៈបច្ចេកទេស បវព សមស្របតាមស្តង់ដារបស់ក្រសួង អ.យ.ក។ | គ្រប់អង្គភាពថ្នាក់ក្រោមជាតិ ត្រូវទទួលបានកម្រិតបញ្ជូនទិន្នន័យ (Bandwidth) សមស្របតាមស្តង់ដារបស់ក្រសួង អ.យ.ក ។ |

| យុទ្ធសាស្ត្រ ១.៤ បញ្ចូលកម្រិតបញ្ជូនទិន្នន័យរបស់បណ្តាញ (Network Bandwidth) រួមគ្នាដើម្បីបង្កើនប្រសិទ្ធភាពការងារ | | |
|---|---|---|
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ១.៤.១ | កំណត់កម្រិតបញ្ជូនទិន្នន័យស្តង់ដាសម្រាប់គ្រឹះស្ថាននីមួយៗទៅតាមប្រភេទ និងទំហំនៃគ្រឹះស្ថានទាំងនោះ។ | បង្កើតបណ្តាញអប់រំជាតិជាផ្នែកមួយនៃមូលនិធិ CBR&D និង USO។ |
| ១.៤.២ | គ្រប់គ្រឹះស្ថានអប់រំទាំងអស់ទទួលបានកម្រិតបញ្ជូនទិន្នន័យសម្រាប់តភ្ជាប់ទំនាក់ទំនង (Connectivity Bandwidth) ទៅតាមស្តង់ដារបស់ក្រសួង អ.យ.ក តាមរយៈមជ្ឈមណ្ឌលប្រតិបត្តិការបណ្តាញនៅថ្នាក់កណ្តាលរបស់ក្រសួង (NOC)។ | |

## ២. អភិបាលកិច្ច និងការគ្រប់គ្រង

| យុទ្ធសាស្ត្រ ២.១ ជំរុញឱ្យមានការប្រើប្រាស់ ការកៀរគរធនធាន និងការរៀបចំផែនការ ផ្អែកតាមភស្តុតាងច្បាស់លាស់តាមរយៈការបង្កភាពងាយស្រួលដល់ការទទួលបានទិន្នន័យ ព័ត៌មាន និងការវិភាគទិន្នន័យ | | |
|---|---|---|
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ២.១.១ | ក្រសួង អ.យ.ក នឹងបង្កើតប្រព័ន្ធទិន្នន័យរួមមួយដើម្បីគាំទ្រដល់ការងារវិភាគលទ្ធផលការងារតាមវិស័យ។ | ប្រព័ន្ធទិន្នន័យរួមរបស់ក្រសួង អ.យ.ក ប្រមូលទិន្នន័យដោយផ្ទាល់ពីប្រភពនានាទាន់ពេលវេលា ដោយបង្កើតនូវរបាយការណ៍តាមកាលកំណត់ស្តីពីលទ្ធផលតាមវិស័យ និងសម្រាប់ផ្សព្វផ្សាយតាមគេហទំព័ររបស់ក្រសួង។ |
| ២.១.២ | អនុវត្តការប្រើប្រាស់កូដដូចៗគ្នាសម្រាប់ទិន្នន័យទាំងអស់របស់ក្រសួង អ.យ.ក ដើម្បីឱ្យមានការវិភាគប្រៀបធៀប និងការតាមដានព័ត៌មាន។ | |
| ២.១.៣ | សម្រួលនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។ បង្កើតការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល និងអនុវត្តនៅតាមការិយាល័យអប់រំ យុវជន និងកីឡា ក្រុង-ខណ្ឌ-ស្រុកទាំងអស់ និងនៅតាមវិទ្យាល័យឱ្យបានចំនួន៥០%។ | អនុវត្តការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថលគ្រប់សាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ និងសាលាមធ្យមសិក្សាបឋមភូមិឱ្យបាន៥០%។ |

| | | |
|---|---|---|
| យុទ្ធសាស្ត្រ ២.២ បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងតាមរយៈការប្រើប្រាស់ដំណើរការប្រតិបត្តិការដោយប្រើប្រព័ន្ធ បពស តាមស្ថាប័នឱ្យមានលក្ខណៈស្តង់ដា | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ២.២.១ | ដាក់ឱ្យប្រើប្រាស់ឧបករណ៍ផលិតភាពដោយប្រើប្រាស់ បពស ដែលមានលក្ខណៈស្តង់ដា ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវប្រតិបត្តិការការងាររបស់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួង អ.យ.ក ។ | ពង្រឹងការប្រើប្រាស់ឧបករណ៍ បពស ដែលមានលក្ខណៈស្តង់ដាដើម្បីធ្វើឱ្យកាន់តែប្រសើរនូវប្រតិបត្តិការការងាររបស់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួង អ.យ.ក ដោយរួមបញ្ចូលទាំងការប្រមូលទិន្នន័យតាមទម្រង់ឌីជីថល។ |
| ២.២.២ | អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាលារៀន ដែលមានលក្ខណៈស្តង់ដានៅតាមសាលាមធ្យមសិក្សាទុតិយភូមិចំនួន៥០%។ | អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានអប់រំដែលមានលក្ខណៈស្តង់ដានៅតាមសាលាមធ្យមសិក្សាទុតិយភូមិដែលនៅសេសសល់ និងតាមសាលាគរុកោសល្យ។ |
| យុទ្ធសាស្ត្រ ២.៣ ធ្វើលទ្ធកម្មកម្មវិធីផ្នែកទន់ដែលចាំបាច់ និងដាក់ចេញនីតិវិធីសម្រាប់ដំណើរការប្រព័ន្ធ បពស សំខាន់ៗរបស់ក្រសួង អ.យ.ក | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ២.៣.១ | ដំណើរការគ្រប់គ្រង និងរដ្ឋបាលអប់រំដោយប្រើប្រាស់ប្រព័ន្ធ បពស ត្រូវបានបង្កើតឡើងក្នុងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងគម្រោង បពស និងពិនិត្យតាមដានប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មានជាប្រចាំ។ | ផ្តល់កម្មវិធីផ្នែកទន់ និងនីតិវិធីសម្រាប់វិភាគ និងគ្រប់គ្រងទិន្នន័យកម្រិតខ្ពស់ដល់គ្រប់អង្គភាពទាំងអស់របស់ក្រសួង អ.យ.ក នៅថ្នាក់ជាតិ។ |
| ២.៣.២ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងផ្តល់ប្រឹក្សាអំពីការធ្វើលទ្ធកម្ម បពស ការសម្របសម្រួល ការគាំទ្របច្ចេកទេសពាក់ព័ន្ធ បពស និងសេវាផ្តល់ជំនួយ (Help-Desk) និងបំពេញតួនាទីជាកន្លែងផ្តល់ការឯកភាពដល់គម្រោង បពស ក្នុងវិស័យអប់រំទាំងអស់។ | បង្កើតកម្មវិធីផ្នែកទន់សម្រាប់គ្រប់គ្រងបណ្ណសារឯកសារ និងដំណើរការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថលនៅគ្រប់អង្គភាពថ្នាក់ជាតិទាំងអស់របស់ក្រសួង អ.យ.ក។ |
| ២.៣.៣ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងបង្កើតផ្នែកសេវាផ្តល់ជំនួយ (Help-Desk) ដើម្បីជួយដោះស្រាយបញ្ហានៅកម្រិតដំបូងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតាមសាលារៀន។ | |

| យុទ្ធសាស្ត្រ ២.៤ សម្របសម្រួល និងធ្វើការត្រួតពិនិត្យលើគ្រប់សកម្មភាព បពស ទាំងអស់ដែលកើតមានក្នុងក្របខ័ណ្ឌឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រនេះ | | |
|---|---|---|
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ២.៤.១ | រាល់ភាគីពាក់ព័ន្ធទាំងអស់ធ្វើការសម្របសម្រួលជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាឱ្យមានការគោរពតាមស្តង់ដារបស់ក្រសួង អ.យ.ក សម្រាប់ការធ្វើលទ្ធកម្មប្រព័ន្ធ បពស សម្ភារៈបច្ចេកទេស និងការរៀបចំប្រព័ន្ធ និងការវិភាគលើចំណាយសរុបសម្រាប់ការទទួលយកភាពជាម្ចាស់។ | |
| ២.៤.២ | បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃ និងយន្តការគណនេយ្យភាពដែលមានលក្ខណៈរឹងមាំដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត និងការបញ្ចូលគ្រប់គម្រោង បពស ទាំងអស់ទៅក្នុងក្របខ័ណ្ឌក្រសួង អ.យ.ក ។ | |
| យុទ្ធសាស្ត្រ ២.៥ អភិវឌ្ឍ ឬធ្វើលទ្ធកម្មកម្មវិធីផ្នែកទន់ដែលចាំបាច់សម្រាប់គាំទ្រដល់ការងារគ្រប់គ្រង | | |
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ២.៥.១ | ធ្វើលទ្ធកម្មកម្មវិធីផ្នែកទន់បណ្ណសារឯកសារ និងផ្នែកទន់សម្រាប់ទាញយកឯកសារផ្លូវការទាំងអស់របស់ក្រសួង អ.យ.ក ។ | ប្រព័ន្ធបណ្ណសារត្រូវបានពង្រីកដើម្បីគ្របដណ្តប់លើគ្រប់ឯកសារទាំងអស់របស់ក្រសួង អ.យ.ក ។ |
| ២.៥.២ | បង្កើតប្រព័ន្ធតាមដានការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនដែលរៀបចំឡើងជាផ្នែកបន្ថែមលើប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ។ | រាល់ភាគីពាក់ព័ន្ធទាំងអស់នឹងទទួលបានព័ត៌មានផ្អែកទៅតាមតម្រូវការជាក់ស្តែងតាមសិទ្ធិដែលបានកំណត់ (Authenticated Access) ក្នុងប្រព័ន្ធតាមដាន ។ |

## ៣. ការផ្តល់មូលនិធិសម្រាប់ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ

យុទ្ធសាស្ត្រ ៣.១ ផ្តល់ធនធានហិរញ្ញវត្ថុរយៈពេលវែងជាប់ជាប្រចាំ ដើម្បីគាំទ្រដល់ដំណើរការ បពស ក្នុងក្របខ័ណ្ឌក្រសួង អ.យ.ក

| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| ៣.១.១ | រៀបចំផែនការរយៈពេលវែងរួមគ្នាជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (យោងតាមមូលនិធិ CBR&D និង USO) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់មូលនិធិចំណាយមូលធនរបស់ដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ទំនាក់ទំនងបណ្តាញជាមួយនឹងខ្ទង់ថវិការបស់ក្រសួង អ.យ.ក ដើម្បីរ៉ាប់រងចំណាយចរន្តក្នុងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ | បន្តរៀបចំផែនការរយៈពេលវែងជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្វែងរកមូលនិធិសម្រាប់ចំណាយមូលធនលើហេដ្ឋារចនាសម្ព័ន្ធ និងចំណាយចរន្តលើការតភ្ជាប់បណ្តាញ។ |
| ៣.១.២ | ក្រសួង អ.យ.ក នឹងស្វែងរកមូលនិធិសម្រាប់ចំណាយចរន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរ៉ាប់រងចំណាយនៃអន្តរាគមន៍កម្មវិធី បពស នានា។ | ដំណើរការរៀបចំមូលនិធិនេះត្រូវបានបញ្ចូលក្នុងផែនការថវិកាជាប្រចាំរបស់ក្រសួង អ.យ.ក ដើម្បីរ៉ាប់រងចំណាយចរន្ត។ |
| ៣.១.៣ | តួអង្គពាក់ព័ន្ធមិនមែនវិស័យសាធារណៈ៨០% ផ្តល់សម្ភារៈបច្ចេកទេសដោយគោរពទៅតាមយថាប្រភេទកំណត់ដោយក្រសួង អ.យ.ក ។ | តួអង្គពាក់ព័ន្ធមិនមែនវិស័យសាធារណៈ១០០% ផ្តល់សម្ភារៈបច្ចេកទេស ដោយអនុលោមតាមយថាប្រភេទកំណត់ដោយក្រសួង អ.យ.ក ។ |

## ៤. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងរៀន

យុទ្ធសាស្ត្រ ៤.១ ធ្វើទំនើបកម្មកម្មវិធីសិក្សា ដើម្បីបញ្ចូលចំណេះដឹង បពស និងបំណិនសតវត្សរ៍ទី២១

| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| ៤.១.១ | កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិផ្តល់បំណិនវិជ្ជាជីវៈ និងបំណិនមុនចូលសិក្សានៅសាកលវិទ្យាល័យដោយប្រើប្រាស់ បពស បន្សីគ្នាជាមួយនឹងចំណេះដឹង បំណិន និងគន្លងអាជីពសម្រាប់សតវត្សរ៍ទី២១។ | |
| ៤.១.២ | កម្មវិធីសិក្សានៅវិទ្យាស្ថានជាតិអប់រំរៀបចំឡើងសម្រាប់គ្រូឯកទេស បពស នៅកម្រិតមធ្យមសិក្សាទុតិយភូមិឱ្យបានសមស្រប និងផ្តល់ការបណ្តុះបណ្តាលអ្នកគ្រប់គ្រងរដ្ឋបាលកម្រិតសាលារៀនលើបំណិន បពស។ | |

| | | |
|---|---|---|
| យុទ្ធសាស្ត្រ ៤.២ ធ្វើលទ្ធកម្ម និង/ឬអភិវឌ្ឍធនធានអប់រំអេឡិចត្រូនិក សម្រាប់ផ្ដល់ការគាំទ្រដល់ការបង្រៀន និងរៀន (មាតិកាអប់រំអេឡិចត្រូនិក) | | |
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ៤.២.១ | កំណត់ និងធ្វើមូលដ្ឋាននីយកម្មធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចរកបានដោយមិនគិតថ្លៃ ដោយបន្សុីធនធានទាំងនេះឱ្យស្របតាមកម្មវិធីសិក្សាជាតិ និងផ្សព្វផ្សាយធនធានទាំងនេះតាមរយៈគេហទំព័រធនធានអប់រំបើកទូលាយ (OER) របស់ក្រសួង អ.យ.ក ។ | អភិវឌ្ឍ ឬធ្វើលទ្ធកម្ម និងផ្សព្វផ្សាយតាមរយៈគេហទំព័រធនធានអប់រំបើកទូលាយរបស់ក្រសួង អ.យ.ក នូវធនធានអប់រំអេឡិចត្រូនិកគ្រប់ប្រធានបទទាំងអស់ដែលពាក់ព័ន្ធនឹង STEM ដែលគេពុំអាចរកឯកសារព័ត៌មានជាភាសាជាតិបាន។ |
| ៤.២.២ | បញ្ចូលគេហទំព័រធនធានអប់រំបើកទូលាយទៅក្នុងគ្រប់ប្រព័ន្ធ បពស របស់សាលាគរុកោសល្យ និងសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់។ | |
| យុទ្ធសាស្ត្រ ៤.៣ អភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់សៀវភៅមគ្គុទ្ទេសក៍ និងឧបករណ៍នានាសម្រាប់ជំនួយដល់គ្រូលើវិធីសាស្ត្រគរុកោសល្យដោយប្រើប្រាស់ បពស សម្រាប់ការបង្រៀននៅតាមសាលាគរុកោសល្យ និងសាលាមធ្យមសិក្សាទុតិយភូមិ | | |
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ៤.៣.១ | រៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅមគ្គុទេសក៍គ្រូ និងកិច្ចតែងការបង្រៀនដែលបញ្ចូល បពស សម្រាប់បង្រៀនមុខវិជ្ជា STEM នៅតាមសាលាមធ្យមសិក្សាទុតិយភូមិ។ | រៀបចំ និងដាក់ឱ្យប្រើប្រាស់សៀវភៅមគ្គុទេសក៍គ្រូ និងកិច្ចតែងការបង្រៀនដែលបញ្ចូល បពស សម្រាប់បង្រៀនមុខវិជ្ជាសំខាន់ៗទាំងអស់នៅតាមសាលាមធ្យមសិក្សាទុតិយភូមិ។ |
| យុទ្ធសាស្ត្រ ៤.៤ លើកទឹកចិត្តឱ្យមានការធ្វើស្វ័យសិក្សាតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) | | |
| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
| ៤.៤.១ | ក្រសួង អ.យ.ក ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) ផ្អែកលើប្រភពកូដចំហ សម្រាប់ការអប់រំនៅគ្រប់ភូមិសិក្សា។ | សាកលវិទ្យាល័យសាធារណៈប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្អែកលើប្រភពកូដចំហដើម្បីផ្ដល់ការអប់រំតាមរយៈការរៀនតាមប្រព័ន្ធអេឡិចត្រូនិក។ |
| ៤.៤.២ | ជំរុញឱ្យមានការប្រើប្រាស់ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកក្នុងកម្មវិធីរៀនពេញមួយជីវិត និងកម្មវិធីសមមូល។ | |

## ៥. ការអភិវឌ្ឍធនធានមនុស្ស

**យុទ្ធសាស្ត្រ ៥.១ បណ្តុះបណ្តាលគ្រូមុខវិជ្ជាឯកទេស បពស សម្រាប់គ្រប់សាលាមធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ**

| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| ៥.១.១ | វិទ្យាស្ថានជាតិអប់រំផ្គត់ផ្គង់គ្រូមុខវិជ្ជាឯកទេស បពស ក្នុងចំនួនចាំបាច់ដល់គ្រប់សាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ ដើម្បីឱ្យគ្រូទាំងនេះអាចបង្រៀនមុខវិជ្ជា បពស និងកសាងសមត្ថភាពឱ្យពួកគេចេះកំណត់ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ បពស តាមសាលារៀន។ | សាលាគរុកោសល្យចាប់ផ្តើមបណ្តុះបណ្តាលគ្រូមុខវិជ្ជាឯកទេស បពស សម្រាប់សាលាមធ្យមសិក្សាបឋមភូមិ។ |

**យុទ្ធសាស្ត្រ ៥.២ ពង្រឹងការបណ្តុះបណ្តាលគ្រូនៅសាលាគរុកោសល្យ តាមរយៈការបញ្ជ្រាប បពស ក្នុងការបង្រៀន-រៀន និងវិធីសាស្ត្រគរុកោសល្យ**

| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| ៥.២.១ | គ្រូនៅសាលាមធ្យមសិក្សាទុតិយភូមិទទួលបានការបណ្តុះបណ្តាលឱ្យប្រើប្រាស់ធនធានអប់រំអេឡិចត្រូនិក។ ការបណ្តុះបណ្តាលដែលប្រើប្រាស់ធនធានអប់រំអេឡិចត្រូនិក ក៏ត្រូវបានបញ្ចូលទៅក្នុងការបណ្តុះបណ្តាលគរុនិស្សិត គរុសិស្សនៅតាមសាលាគរុកោសល្យ។ | សាលាគរុកោសល្យទាំងអស់បង្រៀន និងបង្ហាញជាគំរូពីរបៀបបង្រៀន ដោយប្រើប្រាស់ បពស និងធនធានអប់រំបើកទូលាយក្នុងការបណ្តុះបណ្តាល និងវិក្រឹតការគ្រូ។ |

**យុទ្ធសាស្ត្រ ៥.៣ អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ដើម្បីផលិតធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយគុណភាពខ្ពស់ និងឆ្លើយតបតាមតម្រូវការនៅតាមសាលារៀន**

| | យុទ្ធសាស្ត្ររយៈពេលខ្លី | យុទ្ធសាស្ត្ររយៈពេលមធ្យម |
|---|---|---|
| ៥.៣.១ | ក្រសួង អ.យ.ក បង្កើនសមត្ថភាពកំណត់ និងធ្វើមូលដ្ឋាននីយកម្មធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដែលមានស្រាប់ក៏ដូចជារៀបចំធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដែលមានគុណភាពខ្ពស់សម្រាប់គ្រូបង្រៀនមុខវិជ្ជា STEM នៅតាមសាលាមធ្យមសិក្សាទុតិយភូមិ។ | សមត្ថភាពរបស់បុគ្គលិកនៅសាលាគរុកោសល្យត្រូវបានអភិវឌ្ឍដើម្បីធ្វើការប្រមូល និងកែសម្រួលធនធានតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលគ្រូ។ |
| ៥.៣.២ | គ្រូឧទ្ទេសនៅសាលាគរុកោសល្យ និងតាមសាកលវិទ្យាល័យសាធារណៈបានបង្កើនសមត្ថភាពប្រើប្រាស់ជំនាញប្រើប្រាស់ពហុមេឌៀ (Multimedia) ដើម្បីអភិវឌ្ឍធនធានអប់រំតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយគុណភាពខ្ពស់។ | |

| យុទ្ធសាស្ត្រ ៥.៤ អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ក្នុងការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគ្រប់គ្រងប្រព័ន្ធ និងសេវាបច្ចេកវិទ្យានានា | | |
|---|---|---|
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ៥.៤.១ | សមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ត្រូវបានអភិវឌ្ឍដើម្បីគ្រប់គ្រងអន្តរាគមន៍ថ្មីៗ និងការគ្រប់គ្រងប្រតិបត្តិការបច្ចេកវិទ្យាជាប្រចាំដូចជាការគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ ការគ្រប់គ្រងប្រព័ន្ធ និងកម្មវិធីទាំងអស់។ | សមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ត្រូវបានអភិវឌ្ឍដើម្បីផ្តល់បំណិនខាងការវិភាគទិន្នន័យកម្រិតខ្ពស់ និងឧបករណ៍គ្រប់គ្រង ដែលអាចចូលមើលរាល់ព័ត៌មានដែលមានទាំងអស់។ |
| ៥.៤.២ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងកសាងសមត្ថភាពដើម្បីផ្តល់ប្រឹក្សាអំពីការធ្វើលទ្ធកម្ម បពស សម្របសម្រួលការគាំទ្របច្ចេកទេស បពស និងសេវាផ្តល់ជំនួយ (Help-Desk) និងបំពេញតួនាទីជាកន្លែងផ្តល់ការអនុញ្ញាតសម្រាប់គ្រប់អន្តរាគមន៍ បពស ទាំងអស់ក្នុងវិស័យអប់រំ។ | ការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីជានាលើការគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យកម្រិតបឋម និងការគ្រប់គ្រងប្រព័ន្ធ និងកម្មវិធីផ្នែកទន់ដែលត្រូវបានប្រើប្រាស់។ |
| ៥.៤.៣ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានផ្តល់ការកសាងសមត្ថភាពអង្គភាពដទៃទៀតនៅថ្នាក់ជាតិរបស់ក្រសួង អ.យ.ក ដើម្បីបង្កើតការគ្រប់គ្រងដំណើរការបណ្ណសារឯកសារ និងប្រមូលទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក។ | |
| យុទ្ធសាស្ត្រ ៥.៥ បង្កើនសមត្ថភាពមន្ត្រីជំនាញក្រសួង អ.យ.ក ក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សាដើម្បីផ្តល់ការបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិក | | |
| | យុទ្ធសាស្ត្ររងរយៈពេលខ្លី | យុទ្ធសាស្ត្ររងរយៈពេលមធ្យម |
| ៥.៥.១ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននឹងកសាងសមត្ថភាពដើម្បីផ្តល់ប្រឹក្សាដល់សាលាគរុកោសល្យ សាលាមធ្យមសិក្សាទុតិយភូមិ និងសាកលវិទ្យាល័យនានា គ្រប់ដំណាក់កាលទាំងអស់នៃការផលិត និងការគ្រប់គ្រងវគ្គសិក្សាដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា។ | សាកលវិទ្យាល័យសាធារណៈ និងសាលាគរុកោសល្យមានសមត្ថភាពបង្កើតវគ្គសិក្សារៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក និងអាចធ្វើការគ្រប់គ្រងវគ្គសិក្សាទាំងនេះបាន។ |
| ៥.៥.២ | ក្រសួង អ.យ.ក កសាងសមត្ថភាពមន្ត្រីជំនាញដើម្បីអភិវឌ្ឍ និងផ្តល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសាលារៀនតាមរយៈប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) ដើម្បីគ្រប់គ្រង និងគាំទ្រដល់ការប្រើប្រាស់ប្រព័ន្ធ បពស។ | |

## ការពិនិត្យតាមដាន និងវាយតម្លៃ

ដោយមិនរៀបរាប់លម្អិតពីសកម្មភាពនានា គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំនេះ ផ្តល់ការណែនាំអំពីរបៀបដែលគួរប្រើប្រាស់ បពស ក្នុងប្រព័ន្ធអប់រំទាំងមូល។ គោលនយោបាយ និងយុទ្ធសាស្ត្រនេះ រៀបរាប់ពីអភិក្រមជាប្រព័ន្ធដែលក្រសួង អ.យ.ក និងដៃគូត្រូវគោរពតាមការអនុវត្តអន្តរាគមន៍ បពស របស់ខ្លួន។

ក្នុងន័យនេះការពិនិត្យតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនេះ មានគោលដៅផ្តោតលើភាពអនុលោមនៃអន្តរាគមន៍នានាស្របតាមគោលការណ៍ ដែលត្រូវបានលើកឡើងនៅក្នុងឯកសារនេះ ដើម្បីធានាឱ្យមានការប្រើប្រាស់អភិក្រម ដែលមានការសម្របសម្រួលគ្នាបានល្អនាំឱ្យសម្រេចបានលទ្ធផលរយៈពេលវែងដូចដែលបានរំពឹងទុក។

សកម្មភាពនីមួយៗដែលអនុវត្តក្នុងក្របខ័ណ្ឌនេះត្រូវកំណត់ពីគោលដៅ និងគោលបំណងឱ្យបានច្បាស់លាស់ កំណត់ពីសូចនាករក៏ដូចជាផែនការពិនិត្យតាមដាន និងវាយតម្លៃ។ ការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយនៃយុទ្ធសាស្ត្រនេះនឹងធានាថាសកម្មភាព បពស ក្នុងវិស័យអប់រំដែលត្រូវបានលើកស្នើទាំងអស់ មានក្នុងផែនការការងារក្រសួង។ អន្តរាគមន៍ទាំងនោះបានធ្វើការគណនា និងមានធនធានសម្រាប់ធានាការចំណាយសរុបក្នុងភាពជាម្ចាស់លើអន្តរាគមន៍។

## សេចក្តីសន្និដ្ឋាន

គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំប្រើប្រាស់អភិក្រមដែលមានលក្ខណៈជាប្រព័ន្ធដើម្បីរៀបចំអនុវត្ត និងបន្តរក្សាការវិនិយោគលើ បពស ក្នុងវិស័យអប់រំ។ អភិក្រមដែលមានលក្ខណៈជាប្រព័ន្ធនេះបញ្ចៀសមិនឱ្យមានការអនុវត្តអន្តរាគមន៍បែកខ្ញែកពីគ្នា ត្រួតគ្នា និងជួយកសាងភាពធន់ រួមទាំងនិរន្តរភាពនៃប្រព័ន្ធ បពស សម្រាប់គ្រប់កម្មវិធីអប់រំរបស់ក្រសួង អ.យ.ក។ ឯកសារនេះផ្តល់ការណែនាំសំខាន់ៗអំពីរបៀបពង្រីកការប្រើប្រាស់ បពស ក្នុងវិស័យអប់រំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការផ្តល់បទពិសោធន៍នៃការរៀនសូត្រប្រកបដោយគុណភាពខ្ពស់។

គោលនយោបាយ និងយុទ្ធសាស្ត្រនេះ បង្ហាញពីក្របខ័ណ្ឌដើម្បីលើកទឹកចិត្តដៃគូអភិវឌ្ឍន៍ ភាគីពាក់ព័ន្ធក្នុងវិស័យឯកជន អង្គភាពក្រោមឱវាទ ក្រសួង អ.យ.ក ឱ្យប្រើប្រាស់អភិក្រមរួមដែលមានការសម្របសម្រួលគ្នាបានល្អ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងការបង្កើនប្រសិទ្ធភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកចំណាយពេលវេលាសម្រាប់ការរៀបចំឯកសារនេះ។ ក្រសួងសូមស្នើឱ្យភាគីពាក់ព័ន្ធទាំងអស់ធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាយ៉ាងណាឱ្យអន្តរាគមន៍ បពស ក្នុងវិស័យអប់រំគោរពទៅតាមស្តង់ដា សំដៅជួយកសាងសេវាអប់រំឱ្យកាន់តែមានលក្ខណៈល្អប្រសើរសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអាស៊ី និងវិទ្យាស្ថានបើកទូលាយ ដែលបានផ្តល់ការគាំទ្រដល់ការរៀបចំឯកសារនេះឡើង។




ក្រសួងអប់រំ យុវជន និងកីឡា
អាគារលេខ ៨០ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីមែល៖ info@moeys.gov.kh
គេហទំព័រ៖ www.moeys.gov.kh
ហ្វេសប៊ុក៖ facebook.com/moeys.gov.kh